ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បច្ចេកទេស
# ចិញ្ចឹមកង្កែបក្នុងអាង



រៀបចំដោយ:
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៩



អាសយដ្ឋាន : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០១២ ៩៨ ៨៣ ៣៧

: ០៩៩ ៨៤ ៤៦ ៦៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/Department of Agricultural Extension

គេហទំព័រ : http://www.khmeragri.info





ក្រុមការងារចងក្រង សៀវភៅបច្ចេកទេសកសិកម្ម ស្តីពីការចិញ្ចឹមកង្កែបក្នុងអាងសូមការអធ្យាស្រ័យពីប្រិយមិត្តអ្នកអានផងដែរ បើសិនជាការបោះពុម្ពផ្សាយកូនសៀវភៅបច្ចេកទសកសិកម្ម ជាលើកទី១នេះ នៅមានការខ្វះចន្លោះ ផ្នែកបច្ចេកទេស រូបភាព និងអក្ខរាវិរុទ្ធ រាល់ការខ្វះខាតទាំងនេះ ក្រុមការងារយើងខ្ញុំ សង្ឃឹមថា នឹងទទួលបាននូវការជួយកែលម្អ បំពេញបន្ថែមពីសំណាក់ប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន រាល់ការកែលម្អទាំងអស់នោះ ក្រុមការងារយើងខ្ញុំ នឹងយកទៅចងក្រងសម្រាប់ការបោះពុម្ពផ្សាយជាលើកទី២បន្តទៀត ៗ៕ សូមអរគុណ !

# សៀវភៅ

# ស្ដីពី

# បច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង


## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សហការជាមួយ

## នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សមាសភាពចូលរួមចំណែកផលិតកូនសៀវភៅ
# ស្តីពីបច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង

## I. ទីប្រឹក្សាផ្តល់យោបល់:

១. ឯកឧត្តម **អេង ជាសាន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## II. អ្នករៀបរៀង:

លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## III. អ្នកស្រាវជ្រាវ:

ក្រុមការងានាយកដ្ឋានវារីវប្បកម្ម នៃរដ្ឋបាលជលផល។

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **រស់ គន្ធី** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

២. លោក **អ៊ួន ឡុង់** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

៣. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



## មាតិកា ទំព័រ


១. សេចក្តីផ្តើម.......................................................................................... ១
២. អត្ថប្រយោជន៍នៃការចិញ្ចឹមកង្កែបក្នុងអាង.............................................. ២
៣. លក្ខណៈជីវសាស្រ្តកង្កែប......................................................................... ៣
៣.១. ចំណាត់ថ្នាក់កង្កែប.......................................................................... ៣
៣-២- ប្រភេទកង្កែបចិញ្ចឹម....................................................................... ៣
៣-៣- ការវិវត្តន៍កូនកង្កែប......................................................................... ៤
៣.៤. ចរិកស៊ីចំណី.................................................................................... ៥
៣.៥. លក្ខខណ្ឌមជ្ឈដ្ឋានរស់នៅ................................................................. ៥
៤. ការជ្រើសរើសទីតាំងអាងចិញ្ចឹមកង្កែប...................................................... ៦
៥. ការសាងសង់អាងចិញ្ចឹមកង្កែប................................................................. ៧
៥.១. ប្រភេទអាង....................................................................................... ៧
៥.២. ទំហំអាង.......................................................................................... ៧
៥.៣. លក្ខណៈបាតអាង............................................................................... ៩
៥.៤. ប្រព័ន្ធទុយោបញ្ចេញ បញ្ចូលទឹក.......................................................... ១០
៥.៥. ដំបូលអាងចិញ្ចឹមកង្កែប...................................................................... ១១
៦. ការដឹកជញ្ជូនកូនកង្កែប.......................................................................... ១២
៧. ដង់ស៊ីតេកូនកង្កែបដាក់ចិញ្ចឹម................................................................. ១៣
៨. ចំណី និងការផ្តល់ចំណី............................................................................ ១៣
៨.១ ប្រភេទចំណីស្រស់............................................................................... ១៣
៨.២. ប្រភេទចំណីផ្សំ.................................................................................. ១៤
៨.៣ របៀបគណនាប្រូតេអ៊ីនចំណី.................................................................. ១៥
៨.៤ ប្រភេទចំណីគ្រាប់................................................................................ ១៥
៩. ការគ្រប់គ្រង........................................................................................... ១៧
១០. រដូវកាលចិញ្ចឹមកង្កែប........................................................................... ១៧
១១. ការតាមដានកម្រិតលូតលាស់ និងអត្រារស់ជាមធ្យមរបស់កង្កែបចិញ្ចឹម.......... ១៧
១១.២ ការតាមដានអត្រារស់.......................................................................... ១៨
១២. ជំងឺ និងការព្យាបាល.............................................................................. ១៨
១២.១ ជំងឺ និងការការពារ........................................................................... ១៨
១២.២ ការព្យាបាល..................................................................................... ២១
១៣. ការប្រមូលផល...................................................................................... ២៤
១៤. កត្តាជោគជ័យនៅក្នុងការចិញ្ចឹមកង្កែប...................................................... ២៥

# បច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង

## ១. សេចក្ដីផ្ដើម

កាលពីអំឡុងឆ្នាំ២០១០ ដល់ឆ្នាំ២០១៣ កន្លងមកនេះ យើងបានសង្កេតឃើញថា សកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ជាពិសេសបច្ចេកទេសចិញ្ចឹមកង្កែបនៅក្នុងប្រព័ន្ធអាង តាមមូលដ្ឋាន ជនបទនៅក្នុងខេត្តចំនួនបួនគឺកំពង់ចាម កំពង់ធំ សៀមរាប និងបន្ទាយមានជ័យ បានធ្វើឱ្យកសិករក្រីក្រមានការចាប់អារម្មណ៍ និងចូលរួមចិញ្ចឹមកង្កែបតាមបែបគ្រួសារនេះយ៉ាងច្រើនកុះករ មិនតែប៉ុណ្ណោះកសិករដែលមានបទពិសោធន៍ក្នុងការចិញ្ចឹមកង្កែបជាច្រើនឆ្នាំកន្លងមកនេះបានជួយធ្វើការផ្សព្វផ្សាយបច្ចេកទេសបន្ថែមដល់កសិករដទៃទៀតដែលមានចំណាប់អារម្មណ៍នៅក្នុងការចិញ្ចឹមកង្កែបទាំងនៅក្នុងតំបន់ និងមូលដ្ឋានរបស់ខ្លួន និងតាមបណ្ដាខេត្តផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា។

ដោយឃើញមានការចាប់អារម្មណ៍ពីគ្រប់ស្រទាប់ប្រជាកសិករក្នុងការចង់ចិញ្ចឹមកង្កែបនេះហើយ ទើបមន្ត្រីជំនាញបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផលបានធ្វើការសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាព ឯកសារបច្ចេកទេសចិញ្ចឹមកង្កែបដែលបានផ្សព្វផ្សាយកន្លងមកឱ្យកាន់តែល្អប្រសើរឡើងតាមរយៈការបញ្ចូលនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗបន្ថែមទៀត ដោយសង្ខេប ងាយយល់ និងអាចចងចាំបាន សម្រាប់បន្តផ្សព្វផ្សាយដល់ទាំងកសិករចិញ្ចឹមកង្កែបសិក្សាស្វែងយល់បន្ថែម។

អត្ថបទណែនាំបច្ចេកទេសចិញ្ចឹមកង្កែបនេះ ត្រូវបានរៀបចំកែសម្រួលចងក្រងឡើងវិញ ដោយផ្ដោតជាសំខាន់លើបច្ចេកទេសចិញ្ចឹមកង្កែប តាមបែបប្រពលវប្បកម្មនៅក្នុងប្រព័ន្ធអាងផ្សេងៗដលែកសិករតាមជនបទមានលទ្ធភាពអាចធ្វើទៅបាននិងទទួលបាននូវលទ្ធផលល្អ។ ប្រព័ន្ធអាងទាំងនោះដែលអាចចិញ្ចឹមកង្កែបបានរួមមាន

ដូចជា អាងបេតុង ឬអាងស៊ីម៉ង់ត៍ អាងកៅស៊ូប្លាស្ទិក អាងឬស្សី អាងសង្កសីក្រាលប្លាស្ទិក។ល។ ដោយប្រើប្រាស់ចំណីគ្រាប់ ឬចំណីផ្សំពីសមាសធាតុធម្មជាតិផ្សេងៗ មានស្រាប់តាមមូលដ្ឋានរបស់កសិករអាចរកបាន និងអាចចិញ្ចឹមកង្កែបបានប្រកបដោយសុខភាពល្អ ធំធាត់ លូតលាស់លឿន និងសម្រេចជោគជ័យ ទទួលបាននូវទិន្នផលខ្ពស់ ហើយចិញ្ចឹមនៅក្នុងរយៈពេលខ្លី ចន្លោះពី២ខែ ទៅ៣ខែប៉ុណ្ណោះ នោះយើងនឹងអាចធ្វើការប្រមូលផលបាន។

## ២- អត្ថប្រយោជន៍នៃការចិញ្ចឹមកង្កែបក្នុងអាង

ការចិញ្ចឹមកង្កែបក្នុងអាងមានលក្ខណៈល្អៗជាច្រើន និងផ្តល់អំណោយផល ព្រមទាំងអត្ថប្រយោជន៍មួយចំនួនដល់កសិករ ក៏ដូចជាវារីវប្បករដូចខាងក្រោម៖

- មានលក្ខណៈបច្ចេកទេសនៅក្នុងការចិញ្ចឹមសាមញ្ញៗ ងាយស្រួលដល់កសិករអាចអនុវត្តធ្វើបានដោយប្រើប្រាស់ធនធានធម្មជាតិមានស្រាប់តាមមូលដ្ឋានរបស់ពួកគាត់
- ប្រើប្រាស់ទីធ្លាឬផ្ទៃដីតូចល្មមនៅក្នុងការចិញ្ចឹមដូចជានៅក្នុងបរិវេណជុំវិញផ្ទះរបស់កសិករជាដើម។ល។
- ប្រើប្រាស់បរិមាណទឹកតិចនៅក្នុងការចិញ្ចឹមមួយវគ្គៗ(វដ្តចិញ្ចឹមនីមួយៗ)
- ចិញ្ចឹមនៅក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ កសិករអាចធ្វើការប្រមូលផលបាន
- កសិករអាចងាយរកទិញបាននូវប្រភពកូនពូជនៅតាមមូលដ្ឋានរបស់ពួកគាត់នាពេលបច្ចុប្បន្ននេះ
- កង្កែបមានរស់ជាតិឆ្ងាញ់ និងកម្រិតប្រូតេអ៊ីនខ្ពស់ ព្រមទាំង ជួយជំរុញប្រព័ន្ធរំលាយអាហារបានលឿន
- កង្កែបមានទីផ្សារល្អ និងតម្លៃសេដ្ឋកិច្ចខ្ពស់
- ការចិញ្ចឹមកង្កែប មិនត្រឹមតែអាចជួយបង្កើនប្រាក់ចំណូលគ្រួសារប៉ុណ្ណោះទេ ថែមទាំងអាចជួយកាត់បន្ថយការចាប់កង្កែបពីធម្មជាតិផងដែរ ដែលជាភ្នាក់ងារជួយកម្ចាត់សត្វល្អិតចង្រៃ និងដង្កូវបំផ្លាញដំណាំកសិកម្ម។ល។

## ៣- លក្ខណៈជីវសាស្ត្រកង្កែប

### ៣.១. ចំណាត់ថ្នាក់កង្កែប

ផ្នែក : Chordata

- ថ្នាក់ : Amphibia
  - លំដាប់ : Anura
    - អំបូរ : Ranidea
      - ពូជ : Rana
        - ប្រភេទ : H.tigerinus
          - ឈ្មោះខ្មែរ : កង្កែបកូប ( កង្កែបមាឌធំ )
          - ឈ្មោះវិទ្យាសាស្ត្រ : RANA TIGRINA

### ៣-២- ប្រភេទកង្កែបចិញ្ចឹម

នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថា មានពូជកង្កែបពីរប្រភេទជាសំខាន់ ដែលកសិករបាន និងកំពុងចិញ្ចឹមនៅក្នុងប្រទេសកម្ពុជាយើង នោះគឺពូជដែលបាននាំចូលមកពីប្រទេសថៃ និងពូជនាំចូលពីប្រទេសវៀតណាម ឬពូជចាប់ពីធម្មជាតិនៅក្នុងប្រទេសកម្ពុជាយើង ដែលជាទូទៅ ត្រូវប្រជាពលរដ្ឋយើងហៅថាកង្កែបកូប ឬកង្កែបអូប។ ជាទូទៅ គេសង្កេតឃើញថាពូជកង្កែបកូប ឬកង្កែបធម្មជាតិនេះ មានចរាចរ រស់



ពូជកង្កែបនាំចូលពីប្រទេសថៃ

( RANA RUGULOSA )



ពូជកង្កែបនាំចូលពីប្រទេសវៀតណាម

( RANA TIGRINA )

នៅស្ទើរពាសពេញតាមបណ្តាប្រទេសក្នុងតំបន់អាស៊ី ជាពិសេស ក្នុងបណ្តាប្រទេសអាស៊ីអគ្នេយ៍យើងនេះ ក្រៅពីប្រទេសកម្ពុជា រួមមានដូចជា ឡាវ ថៃឡង់ដ៍ វៀតណាំ ។ល។

### ៣-៣- ការវិវត្តន៍កូនកង្កែប

តាមរយៈការសិក្សាស្រាវជ្រាវ ក៏ដូចជាការធ្វើអង្កេតជាក់ស្តែង បានបង្ហាញឱ្យឃើញថា កូនកង្កែបបានឆ្លងកាត់ដំណាក់កាលជាច្រើន មុនពេលក្លាយជាកូនកង្កែបពូជពេញលក្ខណៈអាចយកទៅចិញ្ចឹមបាន។ ដំណាក់កាលវិវត្តន៍នីមួយៗ របស់កូនកង្កែប និងបង្ហាញជូនលម្អិតដូចខាងក្រោម៖

✔ កូនកង្កែបទើបញាស់ភ្លាម ត្រូវបានគេហៅជាទូទៅថា កូនក្អុកដែលមានស្រកី មានវង្វង់ភ្នែក និងមានចលនាហែលទឹកដោយសារកន្ទុយមានរូបរាង លក្ខណៈសំប៉ែត និងមាត់បើកចំហរ

✔ នៅក្នុងដំណាក់កាលជាកូនក្អុក ស្រកីរបស់វា មានមុខងារសំខាន់គឺសម្រាប់នៅក្នុងការដកដង្ហើម ហើយជាបន្តបន្ទាប់មកទៀត កូនក្អុកចាប់ផ្តើមមានដុះជើងក្រោយនៅពេលវាមានអាយុ២១ថ្ងៃ រួចមានការលូតលាស់ផ្នែកប្រព័ន្ធដកដង្ហើម ពោលគឺការលូតលាស់សួតចេញជារូបរាង ជំនួសឱ្យស្រកីសម្រាប់ដកដង្ហើម

✔ រយៈពេលប្រមាណពីរសប្តាហ៍បន្ទាប់មកទៀត កូនក្អុកចាប់ផ្តើមមានដុះជើងមុខពីរបន្ថែមទៀត ហើយស្របពេលនោះ កន្ទុយរបស់វាក៏ចាប់ផ្តើមរួញជាបន្តបន្ទាប់ផងដែរ ឬហៅថាដាច់កន្ទុយ

✔ នៅដំណាក់កាលចុងក្រោយនេះ ពោលគឺនៅពេលកូនក្អុកបានវិវត្តឈានដល់អាយុ២៨ថ្ងៃ នោះកន្ទុយរបស់វានឹងត្រូវបានដាច់អស់ជាស្ថាពរ ហើយក៏បានក្លាយជាកូនកង្កែបពូជអាចយកទៅចិញ្ចឹមបានដែលខណៈពេលនេះ វាចាប់ផ្តើមរៀន



វដ្តជីវិតកង្កែប

រស់នៅលើគោក។

### ៣.៨. ចរិកស៊ីចំណី៖

ការរស់នៅក្នុងធម្មជាតិ កង្កែបចូលចិត្តស៊ីប្រភេទចំណីមានជីវិតដូចជាៈ ក្តាម ខ្យង កូនក្អាត់ ជន្លេន កំពឹស កូនត្រី ចង្រិត កណ្តូប មេភ្លៀង មេអំបៅ ដង្កូវ ជាពិសេស ក្តាមសកជាដើម។ល។ ពោលគឺពពួកសត្វល្អិតមានជីវិតគ្រប់ប្រភេទដែលមានទំហំតូចជាងវា។ ម្យ៉ាងទៀត កង្កែបក៏ជាប្រភេទសត្វកាច ស៊ីសាច់ជាអាហារ ហើយវាក៏អាចស៊ីគ្នាផងដែរ ករណីពេលឃ្លានចំណី។ អាស្រ័យហេតុនេះ បានជាកសិករ ឬវារីវប្បករ តែងតែធ្វើការជ្រើសរើសកូនកង្កែបពូជមកដាក់ចិញ្ចឹមដែលមានទំហំប៉ុនៗគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីជៀសវាងការស៊ីគ្នាបណ្តាលឱ្យមានការបង្ករបួសស្នាម និងដំបៅ ក៏ដូចជាបង្កឱ្យមានជំងឺផ្សេងៗ។

ម្យ៉ាងទៀត ការរស់នៅក្នុងធម្មជាតិ កង្កែបក៏ជាប្រភេទសត្វមានចរឹកចូលចិត្តស្វែងរកចំណីអាហារនៅពេលយប់ស្ងាត់ ឬទីកន្លែងស្ងាត់គ្មានភាពអ៊ូអរ គ្មានមនុស្សចេញចូលច្រើន ហើយវាក៏ជាប្រភេទសត្វឆាប់ភ័យខ្លាច ឬផ្អើលផងដែរ។ ដោយឡែកចំពោះកង្កែបចិញ្ចឹមវិញ មានចរិកលក្ខណៈស៊ីចំណីខុសប្លែកពីកង្កែបរស់នៅក្នុងធម្មជាតិ ជាប្រភេទកង្កែបដែលបានមកពីការបង្កាត់ ភ្ញាស់នៅតាមកសិដ្ឋានផលិតកូនពូជដែលមានភាពបន្សាំខ្ពស់រួចទៅហើយជាមួយនឹងភាពអ៊ូអរ និងកន្លែងរស់នៅតូចចង្អៀត ហើយវាក៏អាចចេះស៊ីចំណីបានគ្រប់ប្រភេទ ទាំងចំណីរស់មានជីវិត ចំណីផ្សំ និងចំណីគ្រាប់ឬចំណីផលិតចេញពីរោងចក្រដែលនេះជាភាពងាយស្រួលដល់កសិករឬវារីវប្បករអាចធ្វើការចិញ្ចឹមកង្កែបបានទទួលជោគជ័យ។ ប៉ុន្តែ កង្កែបចិញ្ចឹមជាទូទៅវាចូលចិត្តស៊ីប្រភេទចំណីដែលមានលក្ខណៈអណ្តែតលើផ្ទៃទឹកជាងប្រភេទចំណីលិចទឹកនៅបាតអាង។

### ៣.៩. លក្ខខណ្ឌមជ្ឈដ្ឋានរស់នៅ៖

កង្កែបអាចរស់នៅ និងធំធាត់ លូតលាស់ទៅបានល្អ សមស្រប អាស្រ័យដោយកត្តាលក្ខខណ្ឌមជ្ឈដ្ឋានរស់ល្អសមស្រប ជាពិសេសកត្តាគុណភាពទឹកសមស្រប

ដូចបានបង្ហាញ ខាងក្រោម៖

- កំហាប់អំបិល: កង្កែបត្រូវការរស់នៅក្នុងទឹកសាបដែលមានកម្រិតកំហាប់អំបិលទាបជាង៥ ( ៥ភាគពាន់ )
- pH កម្រិតប៉េហាស់: កង្កែបត្រូវការរស់នៅក្នុងទឹកសាបដែលមានកម្រិតប៉េហាស់ចន្លោះ ៦,៥-៨,៥
- ប្រភពទឹក: កង្កែបត្រូវការរស់នៅក្នុងទឹកសាបដែលមានប្រភពមកពីទន្លេ បឹង ស្រះធម្មជាតិ ទឹកអណ្តូង ដែលមានគុណភាពល្អ គ្មានជាតិជូ និងសារធាតុសរីរាង្គស្អុយរលួយ។
- សីតុណ្ហភាពទឹក: កង្កែបត្រូវការរស់នៅក្នុងទឹកសាបដែលមានកម្រិតសីតុណ្ហភាពចន្លោះពី ២៥-៣២°C ហើយសមស្របបំផុតចន្លោះពី២៨-៣០°C

## ៤. ការជ្រើសរើសទីតាំងអាងចិញ្ចឹមកង្កែប

យើងដឹងហើយថា កង្កែបជាប្រភេទសត្វចូលចិត្តរស់នៅទីកន្លែងស្ងាត់ស្ងៀម គ្មានភាពអ៊ូអរ ដែលមានមនុស្សដើរឆ្លងកាត់ច្រើន។ អាស្រ័យហេតុនេះ យើងគួរធ្វើការជ្រើសរើសទីតាំងអាងចិញ្ចឹមកង្កែបដែលមានលក្ខណៈសមស្របដល់កង្កែបមានការលូតលាស់បានល្អដូចខាងក្រោម៖

- ជិតផ្ទះងាយស្រួលមើលថែទាំ ផ្តល់ចំណី និងការគ្រប់គ្រង
- ស្ថិតនៅទីតាំងភ្លឺស្រឡះ គ្មានដើមឈើច្រើនដុះព័ទ្ធជុំវិញ និងមានពន្លឺព្រះអាទិត្យអាចចេញចូលបានល្អ
- ទីតាំងខ្ពស់ល្អ ងាយស្រួលបញ្ចេញកាកសំណល់ទឹកពីអាង ពេលលាងសម្អាតម្តងៗ
- មានទីតាំង ធានាបាននូវសុវត្ថិភាព គ្មានចោរលួច ឬបំផ្លាញ និងមិនលិចទឹកនៅរដូវវស្សា
- និងមានទីតាំងនៅជិតប្រភពទឹក នោះកាន់តែល្អប្រសើរបំផុត។

## ៥. ការសាងសង់អាងចិញ្ចឹមកង្កែប៖

### ៥.១. ប្រភេទអាង៖

ប្រភេទអាងដែលអាចចិញ្ចឹមកង្កែបបាន និងកសិករមានលទ្ធភាពអាចធ្វើបាន រួមមានដូចជា: អាងស៊ីម៉ង់ត៍ អាងឫស្សីក្រាលតង់ប្លាស្ទិក ឬ អាងឈើក្រាលតង់ប្លាស្ទិក ឬ អាងសង្ក័សីក្រាលតង់ប្លាស្ទិក អាងកៅស៊ូប្លាស្ទិក និងអាងធ្វើពីលូអណ្តូងទឹក ។ល។



អាងសាងសង់ពីដើមឫស្សីឬឈើក្រាលតង់ប្លាស្ទិក



អាងសាងសង់ពីស៊ីម៉ង់ត៍





អាងធ្វើពីតង់កៅស៊ូប្លាស្ទិក

### ៥.២. ទំហំអាង៖

យើងអាចធ្វើការសាងសង់ ឬធ្វើអាងចិញ្ចឹមកង្កែបបានទៅតាមលទ្ធភាព និងចំណង់ចំណូលចិត្តរបស់យើងម្នាក់ៗចង់បាន។ ជាទូទៅ យោងតាមបទពិសោធន៍

បច្ចេកទេសបានអនុវត្តកន្លងមក អាងចិញ្ចឹមកង្កែបសមស្រប កសិករអាចធ្វើបាន និង ទទួលលទ្ធផលល្អ មានទំហំចន្លោះពី ៦ ទៅ៣០ម៉ែត្រការ៉េ ដែលរួមមានប្រាំប្រភេទអាង ឬទំហំខុសៗគ្នាដូចខាងក្រោម៖

**ប្រភេទអាងទី១៖**

- ជម្រៅអាង ឬកម្ពស់អាង: ស្ថិតក្នុងចន្លោះពី០.៨ ម៉ែត្រ (៨តឹក) ទៅ ១.២ ម៉ែត្រ ដើម្បីធានាបានពីការលោតចេញរបស់កង្កែបទៅក្រៅអាង
- បណ្តោយអាង: ប្រវែង៣ម៉ែត្រ
- ទទឹងអាង: ប្រវែង២ម៉ែត្រ

**ប្រភេទអាងទី២៖**

- ជម្រៅអាង ឬកម្ពស់អាង: ស្ថិតក្នុងចន្លោះពី០.៨ ម៉ែត្រ (៨តឹក) ទៅ ១.២ ម៉ែត្រ ដើម្បីធានាបានពីការលោតចេញរបស់កង្កែបទៅក្រៅអាង
- បណ្តោយអាង: ប្រវែង៥ម៉ែត្រ
- ទទឹងអាង: ប្រវែង២ម៉ែត្រ

**ប្រភេទអាងទី៣៖**

- ជម្រៅអាង ឬកម្ពស់អាង: ស្ថិតក្នុងចន្លោះពី០.៨ ម៉ែត្រ (៨តឹក) ទៅ ១.២ ម៉ែត្រ ដើម្បីធានាបានពីការលោតចេញរបស់កង្កែបទៅក្រៅអាង
- បណ្តោយអាង: ប្រវែង៥ម៉ែត្រ
- ទទឹងអាង: ប្រវែង៣ម៉ែត្រ

**ប្រភេទអាងទី៤៖**

- ជម្រៅអាង ឬកម្ពស់អាង: ស្ថិតក្នុងចន្លោះពី០.៨ ម៉ែត្រ (៨តឹក)ទៅ ១.២ ម៉ែត្រ ដើម្បីធានាបានពីការលោតចេញរបស់កង្កែបទៅក្រៅអាង
- បណ្តោយអាង: ប្រវែង៦ម៉ែត្រ
- ទទឹងអាង: ប្រវែង៤ម៉ែត្រ

ប្រភេទអាងទី៥៖

✔ ជម្រៅអាង ឬកម្ពស់អាងៈ ស្ថិតក្នុងចន្លោះពី០.៨ ម៉ែត្រ (៨តឹក) ទៅ ១.២ ម៉ែត្រ ដើម្បីធានាបានពីការលោតចេញរបស់កង្កែបទៅក្រៅអាង

✔ បណ្តោយអាងៈ ប្រវែង៦ម៉ែត្រ

✔ ទទឹងអាងៈ ប្រវែង៥ម៉ែត្រ

ទំហំអាងខាងលើនេះ ត្រូវបានបែងចែក ខ័ណ្ឌជាពីរថត ឬជាពីរអាងប៉ុនគ្នា សម្រាប់ធ្វើការញែកបំបែកកូនកង្កែបចេញពីគ្នារវាងកង្កែបធំ និងកង្កែបតូច បន្ទាប់ពីចិញ្ចឹមបានរយៈពេលចាប់ពី៧ ទៅ១០ថ្ងៃ ដើម្បីជៀសវាងការស៊ីគ្នា ពេលខ្វះចំណី ឬពេលវាឃ្លានចំណី។ ប៉ុន្តែ បន្ទាប់ពីកូនកង្កែបមានទំហំធំចន្លោះពី៥០ក្រាម ទៅ៦០ក្រាម នោះការស៊ីគ្នានឹងត្រូវបានកាត់បន្ថយជាបណ្តើរៗ។

៥.៣. លក្ខណៈបាតអាង៖

✔ អាងចិញ្ចឹមកង្កែប ត្រូវរៀបចំឱ្យមានលក្ខណៈជម្រេលបន្តិច ដើម្បីងាយស្រួលបង្ហូរទឹកចេញពីអាង ពេលលាងសម្អាតម្តងៗ

✔ បាតអាងចិញ្ចឹមកង្កែប ត្រូវរៀបចំឱ្យមានលក្ខណៈរលោង រាបស្មើល្អ ដើម្បី




លក្ខណៈបាតអាងចិញ្ចឹមកង្កែប

ជួយកាត់បន្ថយបាននូវភាពកកឹតដងខ្លួនកង្កែប ជាពិសេសផ្នែកពោះរបស់វា ជៀសវាងការកកឹតដាច់រលាត់ស្បែក បង្កឱ្យមានរបួសស្នាម និងដំបៅ ឬបង្កឱ្យមានជំងឺផ្សេងៗ

✔ បន្ទាប់ពីរៀបចំរួចដូចបានរៀបរាប់ខាងលើ នោះយើងគួរក្រាលតង់កៅស៊ូ

ប្លាស្ទិកនៅបាត និងជញ្ជាំងអាងផ្នែកខាងក្រោម មុនពេលដាក់កូនកង្កែបចិញ្ចឹម ដើម្បីជាប្រយោជន៍ ជួយដល់ការកាត់បន្ថយភាពកកិតពោះកង្កែបបន្ថែមទៀត ដែលទាំងអស់នេះ ជាកត្តាសំខាន់ៗនៅក្នុងការចិញ្ចឹមកង្កែបកន្លងមករបស់កសិករដែលទទួលបានភាពជោគជ័យ។

### ៨.៨. ប្រព័ន្ធទុយោបញ្ចេញ បញ្ចូលទឹក

### ៨.៨.១. ប្រព័ន្ធទុយោបញ្ចេញទឹកចោល

✔ ទំហំទុយោប្រើប្រាស់សម្រាប់បញ្ចេញទឹកចោល ពេលលាងសម្អាតអាងម្តងៗគួរមានមុខកាត់ចន្លោះពី៤០មីលីម៉ែត្រ ទៅ៦០ មីលីម៉ែត្រ ហើយត្រូវមានស្បៃសំណាញ់ច្រោះចងភ្ជាប់នៅចុងទុយោផ្នែកខាងក្នុងអាង ដើម្បីការពារកង្កែបអាចចេញទៅក្រៅបាន។

✔ ទុយោបញ្ចេញទឹកចោល ត្រូវរៀបចំតភ្ជាប់ពីបាតអាង កន្លែងទាបបំផុត ដើម្បីអាចបង្ហូរទឹកចេញបានលឿន និងស្អាតល្អ។




ការរៀបចំប្រព័ន្ធទុយោបញ្ចេញទឹកចោលនៅបាតអាងចិញ្ចឹមកង្កែប

### ៨.៨.២ ប្រព័ន្ធទុយោបញ្ចូលទឹក

✔ ទំហំទុយោប្រើប្រាស់សម្រាប់បញ្ចូលទឹកចូលអាងចិញ្ចឹមកង្កែប គួរមានមុខកាត់ចន្លោះពី២១មីលីម៉ែត្រ ទៅ៤០ មីលីម៉ែត្រ ដែលជាទំហំសមស្របអាចប្រើប្រាស់បានពេលលាងសម្អាតអាង ក៏ដូចជាពេលធ្វើការផ្លាស់ប្តូរទឹកថ្មីម្តងៗ និងមានតម្លៃទាបលើទីផ្សារ

✔ ទុយោបញ្ចូលទឹកចូលអាង ត្រូវរៀបចំតភ្ជាប់វានៅផ្នែកខាងលើនៃបាតអាង ឬនៅទីកន្លែងដែលខ្ពស់ជាងបាតអាងដើម្បីងាយស្រួលបង្ហូរទឹកបញ្ចូលអាង។





ការរៀបចំប្រព័ន្ធទុយោបញ្ចូលទឹកចូលអាងចិញ្ចឹមកង្កែប

### ៥.៥. ដំបូលអាងចិញ្ចឹមកង្កែប៖

✔ អាងចិញ្ចឹមកង្កែប ត្រូវរៀបចំប្រក់ដំបូលឱ្យបានត្រឹមត្រូវដើម្បីការពារកម្តៅថ្ងៃ ឬពន្លឺព្រះអាទិត្យចេញចូលអាងមានកម្រិតខ្ពស់ពេក

✔ ម្យ៉ាងទៀត ដំបូលអាងគួរប្រក់ ឬរៀបចំឡើងដោយស្បៃហាប៉ា ឬស្បៃម៉ុងមានពណ៌បៃតង ឬពណ៌ខៀវដែលមានលក្ខណៈល្អសមស្របបំផុត អាចជួយកាត់បន្ថយកម្តៅបានល្អ មិនជក់ទឹក និងប្រើប្រាស់បានយូរឆ្នាំ

✔ ដំបូល គួរប្រក់នៅពីលើអាងចិញ្ចឹមកង្កែប ឱ្យមានរយៈកម្ពស់សមស្រប





លក្ខណៈដំបូលអាងចិញ្ចឹមកង្កែប

ប្រហែល២ម៉ែត្រប៉ុណ្ណោះ តែជៀសវាងទាបជាងនេះដែលបណ្តាលឱ្យខ្យល់មិនអាចចេញចូលបានល្អ។

## ៦. ការដឹកជញ្ជូនកូនកង្កែប

ជាទូទៅ កូនកង្កែបត្រូវបានគេដឹកជញ្ជូនវាដោយប្រើប្រាស់នូវឧបករណ៍ សម្ភារវេចខ្ចប់តាមបែបសាមញ្ញៗមួយចំនួនដូចជា ធុងជ័រ កេះស្នោរ និងកញ្ជេ ។ល។ ដោយមានចោះប្រហោងអាចឱ្យខ្យល់ចេញ ចូលបានគ្រប់គ្រាន់។

ការដឹកជញ្ជូនកូនកង្កែប គួរតែធ្វើឡើងនៅពេលមេឃត្រជាក់ ជាពិសេស នៅពេលយប់ ឬព្រឹកព្រលឹម ដោយស្តុកកូនកង្កែបនូវកម្រិតដង់ស៊ីតេ ឬចំនួនសមស្របដូចបានកំណត់ខាងក្រោម៖

- ✔ ចំពោះកូនកង្កែបទម្ងន់ពី៥ ទៅ ១០ក្រាម នៅក្នុងមួយក្បាល នោះអាចដាក់ស្តុកបានពី៥០០ក្បាល ទៅ៨០០ក្បាល នៅក្នុងមួយម៉ែត្រការ៉េនៃឧបករណ៍ដឹកជញ្ជូន
- ✔ ចំពោះកូនកង្កែបទម្ងន់ពី១០ ទៅ ១៥ក្រាម នៅក្នុងមួយក្បាល នោះអាចដាក់ស្តុកបានពី៤០០ក្បាល ទៅ៥០០ក្បាល នៅក្នុងមួយម៉ែត្រការ៉េនៃឧបករណ៍ដឹកជញ្ជូន
- ✔ ត្រូវផ្អាក ឬឈប់ផ្តល់ចំណីដល់កូនកង្កែបចំនួនមួយថ្ងៃ នៅមុនពេលធ្វើការដឹកជញ្ជូន
- ✔ ត្រូវលាងសម្អាតដងខ្លួនកូនកង្កែបដោយទឹកស្អាត មានចរន្តទឹកបាញ់តិចៗ





របៀបវេចខ្ចប់ និងការដឹកជញ្ជូនកូនកង្កែប

រួចរក្សាវាទុកនៅទីកន្លែងត្រជាក់រយៈពេលពី១០ ទៅ១៥នាទី បន្ទាប់ពីដឹកជញ្ជូនផ្លូវឆ្ងាយ និងលែងចូលអាងចិញ្ចឹម។

## ៧. ដង់ស៊ីតេកូនកង្កែបដាក់ចិញ្ចឹម៖

កូនកង្កែបដែលអាចយកមកដាក់ចិញ្ចឹមបាន គួរមានអាយុចាប់ពី៤០ ទៅ៤៥ ថ្ងៃបន្ទាប់ពីញាស់រួច និង មានទម្ងន់ចន្លោះពី១០ ទៅ១៦ក្រាម នៅក្នុងមួយក្បាល។ កូនកង្កែប បន្ទាប់ពីដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវលាងសម្អាតដោយទឹកស្អាត មានចរន្តទឹកបាញ់តិចៗ រួចរក្សាវាទុកនៅទីកន្លែងត្រជាក់រយៈពេលពី១០ ទៅ១៥នាទី មុនពេលលែងចូលអាងចិញ្ចឹម ហើយយើងអាចដាក់វាចិញ្ចឹមនៅក្នុងកម្រិតដង់ស៊ីតេចន្លោះពី ៨០ទៅ១០០ក្បាល នៅក្នុងមួយម៉ែត្រការ៉េអាង ដែលមានទឹកជម្រៅពី២ ទៅ៥ សង់ទីម៉ែត្រ។




របៀបលែងកូនកង្កែបចូលអាងចិញ្ចឹម

## ៨. ចំណី និងការផ្តល់ចំណី៖

### ៨.១ ប្រភេទចំណីស្រស់៖

ចំពោះប្រភេទចំណីស្រស់ សម្រាប់កង្កែបចិញ្ចឹមនាពេលបច្ចុប្បន្ននេះ រួមមានដូចជា៖ ពពួកត្រីល្អិត ខ្យង ក្តាម ជន្លេន ចង្រិត កាកសំណល់មាន់ ទា។ល។ សុទ្ធតែអាចប្រើប្រាស់ធ្វើជាចំណីកង្កែបបានទាំងនៅស្រស់ និងចម្អិនឆ្អិន។ ប្រភេទចំណីស្រស់ទាំងអស់ខាងលើនេះ យើងប្រើប្រាស់ធ្វើជាចំណីកង្កែប វាមានតម្លៃថោក និងអាចរកបានដោយខ្លួនឯងនៅក្នុងមូលដ្ឋាន មិនចំណាយប្រាក់។ បរិមាណចំណី ផ្តល់ឱ្យកង្កែប

ស៊ី ត្រូវបានបែងចែកជាពីរដំណាក់កាលដូចខាងក្រោម៖

✔ ដំណាក់កាលទី១ ពេលកង្កែបមានទំហំ ចន្លោះពី ៥ ទៅ ១០ ក្រាមនៅក្នុងមួយក្បាល ត្រូវផ្តល់ចំណីពី ៧% ទៅ ១០% ធៀបទម្ងន់ដងខ្លួនកង្កែបចិញ្ចឹមក្នុងអាង ហើយផ្តល់ចំណីចំនួន ពី ៣ ទៅ ៤ដងក្នុងមួយថ្ងៃ

✔ ដំណាក់កាលទី២ ពេលកង្កែបមានទំហំ ចន្លោះពី ១០០ ទៅ ២៥០ ក្រាម នៅក្នុងមួយក្បាល ត្រូវផ្តល់ចំណីពី ៣% ទៅ ៥% ធៀបទម្ងន់ដងខ្លួនកង្កែបចិញ្ចឹមក្នុងអាង ហើយផ្តល់ចំណីចំនួន ពី ២ ទៅ ៣ដងក្នុងមួយថ្ងៃ។





ប្រភេទចំណីស្រស់សម្រាប់ផ្តល់ឱ្យកង្កែប

### ៨.២. ប្រភេទចំណីផ្សំ៖

ចំពោះប្រភេទចំណីផ្សំ សម្រាប់កង្កែបចិញ្ចឹមនាពេលបច្ចុប្បន្ននេះ រួមមានដូចជា៖ ម្សៅត្រី ឬត្រីល្អិត កន្ទក់ ពោត សណ្តែកសៀង អំបិល ។ល។ ជាសមាសធាតុចំណីផ្សំ អាចមានស្រាប់តាមមូលដ្ឋានរបស់កសិករ ឬអាចរកទិញបានតាមមូលដ្ឋាននៅក្នុងតម្លៃថោក។ យើងអាចផ្សំវា រួចចម្អិនសម្រាប់ឱ្យកង្កែបស៊ីបានទៅតាមរូបមន្តដូចខាងក្រោម៖

✔ កន្ទក់៖ ៤០%

✔ ម្សៅត្រី៖ ៤០%

✔ សណ្តែកសៀង៖ ៥%

✔ ពោតក្រហម៖ ១៥%

បរិមាណចំណីត្រូវផ្តល់ចន្លោះពី ៣% ទៅ ៥% ធៀបទម្ងន់ដងខ្លួនកង្កែបចិញ្ចឹមក្នុងអាង ហើយផ្តល់ចំណីចំនួនពី ២ ទៅ ៣ដងក្នុងមួយថ្ងៃ ឬអាចពី៣ទៅ៤ដងក្នុងមួយថ្ងៃនោះកាន់តែល្អប្រសើរ។

### ៨.៣ របៀបគណនាប្រូតេអ៊ីនចំណី៖

ដើម្បីផ្សំចំណីឱ្យបានត្រឹមត្រូវ តាមកម្រិតប្រូតេអ៊ីនដែលយើងចង់បាន នោះត្រូវដឹងជាមុននូវអត្រាប្រូតេអ៊ីនដែលមាននៅក្នុងសមាសធាតុផ្សំចំណីនីមួយៗ និងបរិមាណសមាសធាតុផ្សំចំណីនីមួយៗ ដូចបង្ហាញខាងក្រោម៖

- ម្សៅត្រី ដែលមានកម្រិតប្រូតេអ៊ីន ៦០%
- កន្ទក់ម៉ត់ល្អដែលមានកម្រិតប្រូតេអ៊ីន១២%
- សណ្តែកសៀងមានកម្រិតប្រូតេអ៊ីន៤០%
- ពោតក្រហមមានកម្រិតប្រូតេអ៊ីន៨% ។ល។

ឧទាហរណ៍៖ តើយើងត្រូវប្រើកន្ទក់ សណ្តែកសៀងប៉ុន្មានគីឡូក្រាម? ដើម្បីឱ្យបានចំណីផ្សំមួយ ដែលមានកម្រិតប្រូតេអ៊ីន៣០% ដោយគេដឹងថាកន្ទក់មានកម្រិតប្រូតេអ៊ីន១២% និងសណ្តែកសៀងមានកម្រិតប្រូតេអ៊ីន៤០%។

**ចម្លើយ:** ដើម្បីគណនារកបរិមាណសមាសធាតុផ្សំចំណីខាងលើ យើងត្រូវប្រើរូបមន្តអង្កត់ទ្រូងចតុកោណកែងខាងក្រោម៖

- កន្ទក់ ១២%
- សណ្តែកសៀង ៤០%




ដូច្នេះ យើងបាន៖

- បរិមាណ(ជាភាគរយ%ធៀបបរិមាណសរុប១០០%)កន្ទក់ដែលត្រូវប្រើគឺ ១៨ x ១០០/២៨= ៦៤.២៩%
- បរិមាណ(ជាភាគរយ%ធៀបបរិមាណសរុប១០០%)សណ្តែកសៀងដែលត្រូវប្រើគឺ ១ x ១០០/២៨= ៣៥.៧១%

### ៨.៤ ប្រភេទចំណីគ្រាប់

ចំពោះប្រភេទកង្កែបចិញ្ចឹមនាពេលបច្ចុប្បន្ននេះ យើងអាចចិញ្ចឹមវាបានដោយ

ប្រើប្រាស់ប្រភេទចំណីគ្រាប់ ឬចំណីផលិតចេញពីរោងចក្រ មានលក្ខណៈស្ងួត ហើយអណ្តែតលើផ្ទៃទឹក ងាយស្រួលដល់កង្កែបអាចចាប់យកស៊ីបានអស់ពីក្នុងទឹកនិងជួយកាត់បន្ថយកាកសំណល់ចំណីសល់នៅបាតអាងដែលអាចបណ្តាលឱ្យឆាប់ស្អុយទឹក។

ការផ្តល់ចំណីគ្រាប់ដល់កង្កែប មានការប្រែប្រួលខុសៗគ្នាទាំងបរិមាណចំណីកម្រិតប្រូតេអ៊ីន និងពេលវេលាផ្តល់ចំណីទៅតាមដំណាក់កាលនីមួយៗនៃការវិវត្តន៍របស់កង្កែបដូចមានបង្ហាញតាមរយៈតារាងខាងក្រោម៖

**តារាងផ្តល់ចំណីគ្រាប់ដល់កង្កែបទៅតាមដំណាក់កាលវិវត្តនីមួយៗ**

| ទំហំគ្រាប់ (ម.ម) | កម្រិតប្រូតេអ៊ីន (%) | អាយុកង្កែប (ថ្ងៃ) | បរិមាណចំណី (%) |
|---|---|---|---|
| ១ | ៣៥ | ១៥ ថ្ងៃដំបូង | ៧ - ១០<br>ផ្តល់ពី ៤ ទៅ ៦ដង នៅក្នុងមួយថ្ងៃ |
| ២-២.៥ | ៣០ | ៣០ថ្ងៃ បន្ទាប់ | ៥ - ៧<br>ផ្តល់ពី ៤ ទៅ ៦ដង នៅក្នុងមួយថ្ងៃ |
| ៣-៣.៥ | ២៥ | ៣០ថ្ងៃ បន្ទាប់ | ៣ - ៥<br>ពី ២ ទៅ ៤ដង នៅក្នុងមួយថ្ងៃ |
| ៨-១០.៥ | ២២ | ចាប់ពី៧៥ថ្ងៃ ឡើងទៅ | ៣ - ៥<br>ផ្តល់ពី ២ ទៅ ៣ដង នៅក្នុងមួយថ្ងៃ |





ប្រភេទចំណីគ្រាប់សម្រាប់ចិញ្ចឹមកង្កែប

## ៩. ការគ្រប់គ្រងៈ

នៅក្នុងអំឡុងពេលចិញ្ចឹមកង្កែប យើងត្រូវឧស្សាហ៍ព្យាយាមតាមដាន និងត្រួតពិនិត្យជាប្រចាំ បើពិនិត្យឃើញថា មានកូនកង្កែបណាធាប់ធំជាងគេ នោះត្រូវចាប់យកទៅដាក់ចិញ្ចឹមក្នុងអាងផ្សេងភ្លាម។ ក្រៅពីនេះ យើងត្រូវធ្វើការផ្លាស់ប្តូរទឹកថ្មីឱ្យបានជាប់ជាប្រចាំនូវរៀងរាល់នៅមុនពេលផ្តល់ចំណីដល់កង្កែបពេលព្រឹក និងពេលល្ងាច។ ករណី ពេលមានភ្លៀងខ្លាំង នោះយើងត្រូវបង្ហូរទឹកក្នុងអាងបញ្ចេញចោល និងបញ្ចូលទឹកថ្មីចូលទៅក្នុងអាងវិញភ្លាម ដើម្បីជៀសវាងកង្កែបពុល ឬមានជំងឺបង្កដោយទឹកភ្លៀងនោះ។

## ១០. រដូវកាលចិញ្ចឹមកង្កែប

តាមរយៈបទពិសោធន៍ កន្លងមកនេះ បានបង្ហាញឱ្យឃើញថា ការផលិតកូនកង្កែបពូជទទួលបានលទ្ធផលល្អ និងអាចផ្គត់ផ្គង់កូនពូជបានគ្រប់គ្រាន់ស្ថិតក្នុងចន្លោះពីខែមីនា ដល់ខែតុលា និងការចិញ្ចឹមកង្កែបសាច់ទទួលបានលទ្ធផលល្អ ក៏ដូចជាមានទីផ្សារល្អសម្រាប់លក់ចេញចន្លោះពីខែមេសា ដល់ខែតុលា ដូចមានបង្ហាញជូនក្នុងតារាងលម្អិតខាងក្រោម៖

| លរ | រដូវមានកូនពូជចិញ្ចឹម | រយៈពេលចិញ្ចឹម | សំគាល់ |
|---|---|---|---|
| ១ | ខែ មេសា | ២ ខែកន្លះ | មានទីផ្សារល្អ អាចលក់បានតម្លៃខ្ពស់ |
| ២ | ខែ មិថុនា | ២ ខែកន្លះ | មានទីផ្សារល្អ អាចលក់បានតម្លៃខ្ពស់ |
| ៣ | ខែ សីហា | ២ ខែកន្លះ | មានទីផ្សារល្អ អាចលក់បានតម្លៃខ្ពស់ |
| ៤ | ខែ តុលា | ២ ខែកន្លះ | មានទីផ្សារចង្អៀត និងលក់បានតម្លៃទាប |

## ១១. ការតាមដានកម្រិតលូតលាស់ និងអត្រារស់ជាមធ្យមរបស់កង្កែបចិញ្ចឹម៖

### ១១.១. ការតាមដានកម្រិតលូតលាស់ជាមធ្យម៖

យើងអាចធ្វើការតាមដាន ការលូតលាស់របស់កង្កែបចិញ្ចឹមបាន តាមរយៈការ

ថ្លឹងកង្កែបចាប់ពី១០០ ក្បាលរួចយកវាទៅថ្លឹងរកទម្ងន់សរុប ចែកនឹងចំនួនក្បាលសរុបដែលបានថ្លឹង។ ផលចែកទទួលបាននោះ គឺជាទម្ងន់មធ្យមរបស់កង្កែបនៅក្នុង១ក្បាល។ ការតាមដានដំណើការលូតលាស់របស់កង្កែប យើងអាចធ្វើឡើងរៀងរាល់មួយខែម្តង ដោយប្រើដៃចាប់ផ្ទាល់មុននឹងផ្តល់ចំណី។ ខាងក្រោមជារូបមន្តសម្រាប់គណនារកកម្រិតលូតលាស់ជាមធ្យមរបស់កង្កែប៖

កម្រិតលូតលាស់ ឬ ទម្ងន់កង្កែបជាមធ្យម (ក្រាម) = ទម្ងន់កង្កែបសរុប (ក្រាម) / ចំនួនកង្កែបសរុប (ក្បាល)

### ១១.២ ការតាមដានអត្រារស់៖

យើងអាចធ្វើការតាមដានពីអត្រារស់របស់កង្កែបចិញ្ចឹម ដោយធ្វើការចាប់រាប់កង្កែបនៅក្នុងអាងទាំងអស់ រួចយកចំនួនសរុបដែលបានរាប់នោះ ទៅគុណនឹង១០០ ហើយចែកនឹងចំនួនកង្កែបសរុបទាំងអស់ដែលបានដាក់ចិញ្ចឹម។ លទ្ធផលនៃផលចែកសរុបនោះគឺជាអត្រារស់របស់កង្កែបបានចិញ្ចឹមគិតជាភាគរយ(%)។

ជាទូទៅ ការគណនារកអត្រារស់នៃកង្កែបចិញ្ចឹម គឺត្រូវបានធ្វើឡើង នៅពេលប្រមូលផលសរុបចុងក្រោយ។ ករណី អត្រារស់របស់កង្កែបចិញ្ចឹមកាន់តែទាប នោះធ្វើឱ្យផលចំណេញពីការចិញ្ចឹមកង្កែបកាន់តែថយចុះ ឬ អាចខាត។ ការតាមដានពីអត្រារស់របស់កង្កែបចិញ្ចឹមនេះ មានអត្ថប្រយោជន៍ខ្លាំងណាស់ អាចឱ្យយើងធ្វើការឆ្លុះបញ្ចាំងបានពីកំហុសឆ្គងផ្សេងៗនៃការអនុត្តន៍បច្ចេកទេសកន្លងមក និងទទួលបាននូវបទពិសោធន៍កាន់តែច្រើនបន្ថែមទៀត សម្រាប់ការចិញ្ចឹមពេលក្រោយដោយមានការកែលម្អឡើងវិញ និងអាចទទួលបាននូវលទ្ធផលចិញ្ចឹមកាន់តែប្រសើរ អត្រារស់កាន់តែខ្ពស់ ដែលនាំឱ្យការចិញ្ចឹមកង្កែបនាពេលខាងមុខកាន់តែទទួលបានផលចំណេញច្រើន។ ខាងក្រោមនេះជារូបមន្ត សម្រាប់គណនារកអត្រារស់របស់កង្កែប៖

អត្រារស់ (%) = ចំនួនកង្កែបនៅសល់សរុប (ក្បាល) × ១០០ / ចំនួនកង្កែប ដែលបានដាក់ចិញ្ចឹម (ក្បាល)

## ១២. ជំងឺ និងការព្យាបាល៖

### ១២.១ ជំងឺ និងការការពារ៖

ជំងឺកង្កែបចិញ្ចឹមតែងតែជួបប្រទះ ជាទូទៅបង្កឡើងដោយកត្តាគុណភាពទឹកមិនល្អ ឬកខ្វក់ ដែលប្រើប្រាស់នៅក្នុងការចិញ្ចឹមកង្កែប និងចំណីគ្មានគុណភាព ព្រមទាំងនៅក្នុងអំឡុងពេលចិញ្ចឹម មិនបានធ្វើអនាម័យបាតអាង បានទៀងទាត់ និងស្អាតល្អជាប្រចាំ។ ជំងឺកង្កែបដែលតែងតែជួបប្រទះនោះគឺជំងឺហើមពោះ និងជំងឺរលាកស្បែក។

### ក. ជំងឺហើមពោះ៖

✔ ពោះកង្កែបមានលក្ខណៈរីកធំ បណ្តាលឱ្យកង្កែបឈប់ធ្វើចលនា ឬមានចលនាតិចតួច និងកាត់បន្ថយសកម្មភាពស៊ីចំណី ឬរកចំណី។

✔ ករណីខ្លះ គេសង្កេតឃើញថា កង្កែបមួយចំនួនអាចលានក្រសាលគូទចេញមកក្រៅ។

### មូលហេតុបង្ក៖

✔ បង្កដោយពពួកប្រូតូសូអ៊ែរ ដូចជា ពពួកដង្កូវពោះវៀន

✔កង្កែបស៊ីចំណីផ្អូម( ចំណីសល់ )ឬស៊ីចំណីច្រើនពេកហើយមិនអាចបញ្ចេញលាមកបាន

✔ ទឹកក្នុងអាងចិញ្ចឹមខូចគុណភាព បណ្តាលមកពីមិនបានផ្លាស់ប្តូរទឹកថ្មីបានទៀងទាត់។

### វិធានការណ៍ការពារ៖

✔ ត្រូវខស្សាហ៍ ព្យាយាមធ្វើការផ្លាស់ប្តូរទឹកថ្មី ឱ្យបានទៀងទាត់ និងសម្អាតបាតអាងឱ្យបានជាប់ជាប្រចាំ









✔ ត្រូវលាយថ្នាំអង់ស៊ីម (Enzymes) ឬ Lactobacillus បរិមាណពី២ ទៅ ៣ ក្រាម ក្នុង១គីឡូក្រាម ចំណី ប្រើរយៈពេលពី ៤ ទៅ ៥ថ្ងៃ ម្តង។

## ខ. ជំងឺរលាកស្បែក៖

✔ កង្កែបកាត់បន្ថយសកម្មភាពស៊ីចំណី និងមានចលនាយឺតៗ

✔ នៅលើដងខ្លួនកង្កែប ផ្ទៃពោះ និងជើងខាងក្រោមរបស់វា មានស្នាមជាំពណ៌ក្រហម ជាពិសេស នៅលើប្រអប់ជើងទាំងបួន បើយកមកវះ នោះយើងនឹងឃើញសាច់របស់វាមានពណ៌ក្រហមជាំ។

### មូលហេតុបង្ក៖

✔ បណ្តាលមកពីបាក់តេរី ឈ្មោះអាអេរ៉ូម៉ូណាស់ អ៊ីដ្រូភីឡា (Aeromonas Hydrophila)

✔ បាតអាងចិញ្ចឹមកង្កែបមានលក្ខណៈគ្រើមខ្លាំង (អាងស៊ីម៉ង់ត៍) ។

✔ គុណភាពទឹកក្នុងអាងចិញ្ចឹមកង្កែប មានភាពកខ្វក់ខ្លាំងធ្វើឱ្យមេរោគអាចជ្រាបចូលក្នុងខ្លួនកង្កែបតាមរយៈ ស្នាមរបួស អាចបណ្តាលឱ្យកង្កែបមានជំងឺ។

### វិធានការណ៍ការពារ

✔ ត្រូវឧស្សាហ៍ ធ្វើការផ្លាស់ប្តូរទឹកថ្មី ឱ្យបានទៀងទាត់ និងរក្សាគុណភាពទឹកក្នុងអាងឱ្យបានល្អជាប្រចាំ

✔ ផ្ទៃបាតអាង ត្រូវរៀបចំឱ្យមានលក្ខណៈរលោង

✔ ត្រូវលាងសម្អាតបាតអាងចិញ្ចឹមកង្កែបបានស្អាតជាប្រចាំ។

 

កង្កែបក្រោយពេលវះរួច

## ១២.២ ការព្យាបាល៖

ជំងឺកង្កែប យើងអាចធ្វើការព្យាបាលវាបានដោយប្រើប្រាស់ប្រភេទថ្នាំពេទ្យ ឬអាចប្រើថ្នាំផ្សំពីរុក្ខជាតិ។ ជាក់ស្តែង តាមបទពិសោធន៍កន្លងមក យើងបានណែនាំឱ្យកសិករបានប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិចំនួនពី៣ ទៅ៤មុខដែលងាយរកបាននៅតាមមូលដ្ឋានរបស់ពួកគាត់។

### ១២.២.១ ប្រភេទថ្នាំផ្សំពីរុក្ខជាតិ៖

#### ក. ថ្នាំផ្សំពីរុក្ខជាតិសម្រាប់ព្យាបាលជំងឺហើមពោះ៖

- មើមរមៀត ចំនួន ២គីឡូក្រាម
- គល់ស្លឹកគ្រៃ ចំនួន ២គីឡូក្រាម
- ស្លឹកម្រះព្រៅ ចំនួន ២គីឡូក្រាម
- ស្លឹកវល្លិ៍ត្រចៀកក្រាញ់ ចំនួន ២គីឡូក្រាម។






**វិធីផ្សំ៖**

- លាងសម្អាតរាល់វត្ថុធាតុដើមទាំងអស់ រួចសំដិលទុកឱ្យស្រក់ទឹកអស់
- បុករាល់វត្ថុធាតុដើម រួចលាយច្របល់ចូលគ្នាឱ្យបានសព្វល្អ
- ផ្អាប់វត្ថុធាតុដើមដែលបានច្របល់ចូលគ្នា រួចរក្សាទុករយៈពេលពី៥ទៅ៧ថ្ងៃ ។ ក្នុងកំឡុងពេលនេះ ទឹកថ្នាំជោចេញពីវត្ថុធាតុដើមទាំងនោះ ដែលយើងហៅថាជាថ្នាំផ្សំពីរុក្ខជាតិ សម្រាប់ព្យាបាលជំងឺហើមពោះ។

**វិធីប្រើ និងរយៈពេលប្រើ៖**

- ប្រើទឹកថ្នាំពី ៣ ទៅ ៥ មីលីលីត្រ លាយជាមួយចំណីគ្រាប់ចំនួន៥ គីឡូក្រាម
- សំដិលចំណីដែលបានលាយថ្នាំរួច ហើយទុកឱ្យស្ងួត
- យកចំណីដែលបានលាយថ្នាំ ឱ្យកង្កែបស៊ីរយៈពេលពី២ ទៅ៣ថ្ងៃជាប់គ្នា។ ក្រោយរយៈពេលពី ៧ទៅ ១០ថ្ងៃ គួរឱ្យវាស៊ីម្តងទៀត។

### ខ. ថ្នាំផ្សំពីរុក្ខជាតិសម្រាប់ព្យាបាលជំងឺរលាកស្បែក៖

- ✔ សំបកដើមអង្គារដី ចំនួន ២គីឡូក្រាម
- ✔ អំបិលគ្រួស ចំនួន ០.៣គីឡូក្រាម
- ✔ ទឹកស្អាត ចំនួន ១០លីត្រ។









### វិធីផ្សំ និងរបៀបប្រើ៖

- ✔ បុក ឬជំសំបកដើមអង្គារដីឱ្យទក់ រួចយកទៅត្រាំទឹកស្អាត ១០លីត្រ
- ✔ ត្រាំរយៈពេលពី២ទៅ៣ថ្ងៃ
- ✔ យកទឹកដែលបានត្រាំសំបកអង្គារដីមានចំណុះ១០លីត្រនោះមកលាយជាមួយអំបិលពី ២ ទៅ ៣ខាំ ឱ្យសព្វល្អ រួចយកទៅបាច ឬ ប្រស់ទៅលើកង្កែបផ្ទាល់។ ប្រហែល១០នាទីក្រោយមក យើងបាញ់ទឹកធម្មតាលាងសំអាតវិញ។ ធ្វើតាមវិធីនេះ ពី ១៥ ទៅ ៣០ថ្ងៃម្តង។

### ១២.២.២ ប្រភេទថ្នាំពេទ្យ៖

#### ក. ជំងឺហើមពោះ៖

- ប្រើ Metronidazle ចំនួន ពី ២ ទៅ ៣ ក្រាម សម្រាប់លាយជាមួយចំណី ១គីឡូក្រាម ឱ្យកង្កែបស៊ីពី៣ ទៅ ៥ ថ្ងៃ
- ឬអាចប្រើ Sulphadiazin ចំនួនពី២ ទៅ ៣ ក្រាម សម្រាប់លាយជាមួយចំណី ១គីឡូក្រាម ឱ្យកង្កែបស៊ី ពី៣ ទៅ ៥ ថ្ងៃ។

#### ខ. ជំងឺរលាកស្បែក៖

- ប្រើ Oxytetracycline ចំនួន ពី២ ទៅ ៣ក្រាម សម្រាប់លាយជាមួយចំណី ១គីឡូក្រាម ឱ្យកង្កែបស៊ី ពី៣ ទៅ ៥ ថ្ងៃ
- ឬ អាចប្រើ Norfloxaxine ចំនួន ៥ក្រាម សម្រាប់លាយជាមួយចំណី ១ គីឡូក្រាម ឱ្យកង្កែបស៊ី ពី៣ ទៅ ៥ ថ្ងៃ។

## ១៣. ការប្រមូលផល៖

ជាទូទៅ ការចិញ្ចឹមកង្កែប នៅក្នុងរយៈពេលពី ២ខែកន្លះ ទៅ ៣ខែ អាចធ្វើការប្រមូលផលបាន តែបើក្នុងករណី យើងបន្តចិញ្ចឹមរយៈពេលយូរជាងនេះ នោះភាគរយចំណេញនឹងត្រូវបានថយចុះ។ ជាធម្មតា យើងតែងតែធ្វើការប្រមូលផលសរុបតែម្តងដោយមិនចំណាយពេលច្រើនដងនៅក្នុងការប្រមូលផល ពោលគឺការប្រមូលផលរំលស់ និងប្រមូលផលសរុប។ កង្កែបដែលល្អសមស្របសម្រាប់បម្រើឱ្យទីផ្សារ គឺគួរមានទំហំពី៤ ទៅ ៥ក្បាល នៅក្នុង ១គីឡូក្រាម ដែលមានទម្ងន់ជាមធ្យមពី១ ទៅ ២ខាំនៅក្នុងមួយក្បាល។

ជាទូទៅ យើងអាចធ្វើការចិញ្ចឹមកង្កែបបានពី ៣ ទៅ ៤ ដង នៅក្នុងរយៈពេល ១ឆ្នាំ។ អាស្រ័យហេតុនេះ ការប្រមូលផលក៏អាចទទួលបានពី៣ ទៅ៤ដងផងដែរនៅក្នុងមួយឆ្នាំ។ ជារៀងរាល់ឆ្នាំកង្កែបសាច់អាចលក់បានតម្លៃ ចន្លោះពី ៨០០០ ទៅ ១២០០០ រៀល នៅក្នុង១គីឡូក្រាម លើកលែងតែការប្រមូលផល នៅចន្លោះ ពីខែវិច្ឆិកាដល់ ខែមករាតែប៉ុណ្ណោះ ដែលទីផ្សារកង្កែបចិញ្ចឹមមានលក្ខណៈតូចចង្អៀតជាង ហើយ

មានតម្លៃទាប ដោយហេតុថា នារដូវកាលនេះសម្បូរទៅដោយកង្កែបចាប់មកពីតាមធម្មជាតិ។









## ១៤. កត្តាជោគជ័យនៅក្នុងការចិញ្ចឹមកង្កែប៖

តាមរយៈការអនុវត្តលើការងារចិញ្ចឹមកង្កែបកន្លងមក ជាពិសេស នៅក្នុងអំឡុងឆ្នាំ២០១០ ដល់ឆ្នាំ២០១៣ ជាពេលវេលាសកម្មនៅក្នុងការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមកង្កែបដល់កសិករតាមជនបទក្នុងតំបន់ ខេត្តគោលដៅទាំងបួនគឺកំពង់ចាម កំពង់ធំ សៀមរាប និងបន្ទាយមានជ័យ ឃើញថា ការសម្រេចបានជោគជ័យ នៅក្នុងការចិញ្ចឹមកង្កែបគឺត្រូវមានការពឹងផ្អែកលើកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ត្រូវជ្រើសរើសទីតាំងសាងសង់អាងចិញ្ចឹមកង្កែបនៅទីវាលស្រឡះល្អ គ្មានដើមឈើដុះព័ទ្ធជុំវិញដែលធ្វើឱ្យខ្យល់ និងពន្លឺព្រះអាទិត្យអាចចេញចូលបានល្អ
- ត្រូវសាងសង់អាងចិញ្ចឹមកង្កែបឱ្យស្របទៅតាមលក្ខណៈបច្ចេកទេសបាន

ណែនាំ ជាពិសេសត្រូវរៀបចំជញ្ជាំង និងបាតអាងមានលក្ខណៈរលោង រាបស្មើដើម្បីជៀសវាងការកកឹតដងខ្លួន ពោះកង្កែបបង្កស្នាមរបួស និងដំបៅ ឬជំងឺផ្សេងៗ

- ត្រូវជ្រើសរើសកូនពូជកង្កែបមានគុណភាពល្អ គ្មានស្នាមរបួស ទំហំ និងអាយុប៉ុនៗគ្នាមកដាក់ចិញ្ចឹម
- ត្រូវកំណត់ដង់ស៊ីតេ ឬចំនួនកូនកង្កែបចិញ្ចឹមឱ្យបានសមស្រប ពោលគឺមិនត្រូវដាក់កូនកង្កែបចិញ្ចឹមលើសពី១០០ក្បាល នៅក្នុង ១ ម៉ែត្រការ៉េ នៃអាង
- ត្រូវផ្តល់ចំណីដែលមានគុណភាពល្អដល់កង្កែប មានកម្រិតប្រូតេអ៊ីនខ្ពស់លើសពី២២%ឡើងទៅ និងគ្រប់គ្រាន់ ទៀងទាត់តាមពេលវេលាបានកំណត់
- ត្រូវធ្វើការលាងសម្អាតបាតអាង និងផ្លាស់ប្តូរទឹកថ្មីឱ្យបានទៀងទាត់ជាប្រចាំ ដើម្បីជៀសវាងការបង្កឱ្យមានជំងឺផ្សេងៗដល់កង្កែប
- ត្រូវឧស្សាហ៍ព្យាយាម តាមដាន ត្រួតពិនិត្យជាប្រចាំនូវសកម្មភាពរស់នៅរបស់កង្កែប បើសង្កេតឃើញថា មានកង្កែបណា មានទំហំធំជាងគេ នោះត្រូវចាប់បំបែកវាចេញទៅដាក់ចិញ្ចឹមនៅអាងផ្សេងទៀត
- ការចិញ្ចឹមកង្កែប ត្រូវមានវិធានការណ៍ ការពាជាមុន នោះជាកត្តាសំខាន់ដើម្បីឈានទៅរកភាពជោគជ័យ៕





# ឯកសារយោង៖


1. Ouch Lang, 2014. Lecture on frog culture techniques in tanks system. Phnom Penh, Cambodia.
2. P. Sereywath & O. LangTechnical, 2013. Technical manual on frog Culture Technique: Technology and Economic.  FAO-EU Food Security Project, GCP/CMB /039/EC & TCP/CMB/3403
3. S. Saopheak 2013. Technical manual on Frog Culture Techniques in Tanks. Tonle Sap Technology Demonstrations for Productivity Enhancement Projeft-MAFF, Phnom Penh, Cambodia.




